# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ២០១ ព្រទ-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើជូន**

**លោកប្រធានតុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីគោលការណ៍បង្ក្រាបបទល្មើសមួយចំនួន ។

**យោង:** លិខិតណែនាំលេខ ៩៧៨-ព្ររ.៣.២-៩៧ ចុះថ្ងៃទី១០-៩-៩៧ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានធ្វើលិខិតណែនាំដូចមានយោងខាងលើដើម្បីចាត់វិធានការបង្ក្រាបអំពើល្មើសមួយចំនួន ដែលកំពុងតែធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសាធារណៈយ៉ាងធ្ងន់ធ្ងររួចមកហើយប៉ុន្តែរហូតមកដល់ថ្ងៃនេះក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អំពើល្មើសទាំងនោះនៅតែគំរាមគំហែងដល់សន្តិសុខសាធារណៈដដែលពុំទាន់បានចុះថយនៅឡើយ ។

ផ្អែកតាមសភាពការណ៍បច្ចុប្បន្ន អំពើល្មើសដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសាធារណៈយ៉ាងធ្ងន់ធ្ងរគឺបង្ករឡើងដោយក្រុមជនទុច្ចរិតដែលបានប្រព្រឹត្តចាប់មនុស្សជំរិតយកប្រាក់ គំរាមគំហែងទារប្រាក់តាមទូរស័ព្ទឬតាមសំបុត្រ ព្រមទាំងអំពើប្លន់ប្រដាប់អាវុធដែលបានធ្វើឱ្យប្រជារាស្ត្រស្លុតត្រង់ព្រមទាំងអ្នកវិនិយោគទុនបរទេសមានការភ័យខ្លាចយ៉ាងខ្លាំងសឹងមិនហ៊ានមករកស៊ីនៅប្រទេសយើង ។ ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការបំបាត់ភាពភ័យខ្លាចទាំងនេះជូនប្រទេសជាតិយើង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌សូមធ្វើការណែនាំដល់ចៅក្រមទាំងអស់នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវតែអនុវត្តច្បាប់ឱ្យបានតឹងរឹងជាទីបំផុត ចំពោះប្រភេទជនល្មើសខាងលើនេះដូចតទៅៈ

១-ដាច់ខាតមិនត្រូវឱ្យជនល្មើសនៅក្រៅឃុំទោះបីមានអន្តរាគមន៍ឬមានប្រាក់ធានាយ៉ាងណាក៏ដោយ

២-ត្រូវផ្តន្ទាទោសជាអតិបរមាចំពោះជនល្មើស

៣-មិនត្រូវឱ្យជនល្មើសបានរួចខ្លួនដោយប្រការណាមួយឡើយ ជាពិសេសមិនត្រូវឱ្យមានការភាន់ច្រឡំពីអ្នករងគ្រោះទៅជាជនល្មើស ហើយពីជនល្មើសទៅជាអ្នករងគ្រោះវិញទេ ។

៤-អនុវត្តន៍សេចក្តីណែនាំលេខ ៩៧៨.ព្ររ.៣.២-៩៧ ចុះថ្ងៃទី១០-០៩-៩៧ របស់ក្រសួងយុត្តិធម៌ ឱ្យបានតឹងរឹង និងមានប្រសិទ្ធិភាពខ្ពស់បន្តទៀត ។

សេចក្តីណែនាំនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

ចម្លងជូន
- -តុលាការកំពូល និងមហាអយ្យការ
- -សាលាឧទ្ធរណ៍ និងមហាអយ្យការ
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ដើម្បីជ្រាប ។